00797502

លេខ / No: D114

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស និង ០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម **Laurent KASPER-ANSERMET**

កាលបរិច្ឆេទ ៖ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

# កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគី ស្តីអំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤

<u>សហព្រះរាជអាជ្ញា</u>

លោកស្រី ជា លាង

លោក Andrew CAYLEY

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 4 / 04 / 2012
ម៉ោង (Time/Heure) : 3:46 pm
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

00797503

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. និង០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No:D114

**យើង Laurent Kasper-Ansermet** សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

**បានឃើញ**កិច្ចព្រមព្រៀងចុះហត្ថលេខា កាលពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលបានប្រព្រឹត្តអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“កិច្ចព្រមព្រៀង អ.វ.ត.ក”)

**បានឃើញ**ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)

**បានឃើញ**វិធាន ២១ និងវិធាន ៥៥ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)

**បានឃើញ**ការស៊ើបសួរលើជនសង្ស័យចំនួនប្រាំរូប ពាក់ព័ន្ធនឹងបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាត បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា៥០០ មាត្រា ៥០១ មាត្រា ៥០៣ មាត្រា ៥០៥ មាត្រា ៥០៦ មាត្រា៥០៧ និងមាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

**បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ និងទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤[1]

**បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ និងថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[2]។

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ របស់សហព្រះរាជអាជ្ញាស្តីពីកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សំណុំរឿង០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស D1, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សំណុំរឿង០០៤/២០-១១-២០០៨-អ.វ.ត.ក-ក.ស.ច.ស ឯកសារលេខ D1។

## I. គោលបំណងនៃកំណត់សម្គាល់

1. កំណត់សម្គាល់នេះបង្ហាញពីអត្ថិភាពនៃភាពមិនប្រក្រតីយ៉ាងធ្ងន់ធ្ងរ និងស្ថានការណ៍នៃភាពមិនអាចដំណើរបាន ដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង ០០៣ និងសំណុំរឿង០០៤ និងបង្ហាញអំពីច្បាប់ជាធរមាន (I) និងដំណើររឿងនៃហេតុការណ៍នានាដែលបានកើតឡើង ចាប់ពីពេលលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានមកដល់ការិយាល័យរបស់គាត់ (II)។

## II. ច្បាប់ជាធរមាន

2. រាល់បទប្បញ្ញត្តិនៃច្បាប់ដែលអាចអនុវត្តបាន ក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអ.វ.ត.ក ចែងអំពីដំណើរការល្អនៃកិច្ចការរដ្ឋបាលរបស់តុលាការ និងការអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់ ដោយរួមបញ្ចូលទាំងដំណាក់កាលស៊ើបអង្កេត មុនពេលសវនាការ។ មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.កចែងថា "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀតជាបរទេស ដែលហៅថាសហចៅក្រមស៊ើបអង្កេត ដោយអនុវត្តតាមនីតិវិធីដែលនៅជាធរមាន"។

3. ស្រដៀងគ្នានេះដែរ កិច្ចព្រមព្រៀងស្តីពីការបង្កើតអ.វ.ត.ក ចែងថា សហចៅក្រមស៊ើបអង្កេត "ទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត [...] ត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់មិនលម្អៀង និងសុចរិត [...] ត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពមួយផ្សេងទៀតបានឡើយ។ [សហចៅក្រមស៊ើបអង្កេត] ត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។

4. វិធានផ្ទៃក្នុងនៃអ.វ.ត.ក និងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ *ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព* ដោយគិតដល់

---

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋ និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ និងថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ សំណុំរឿង០០៤/២០-១១-២០០៨-អ.វ.ត.ក-ក.ស.ច.ស ឯកសារលេខ D27 និង D65។

00797505



លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[3]។ គោលការណ៍ជាសារវ័ន្តនេះត្រូវអនុវត្តជាគោលការណ៍ណែនាំក្នុងការធ្វើសេចក្ដីសម្រេចទាំងអស់ ដោយសហចៅក្រមស៊ើបអង្កេតក្នុងការបំពេញមុខងាររបស់ខ្លួន ដែល"*អាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត*"[4]។

5. លើសពីនេះ វិធាន ២១ (១) ក៏ចែងផងដែរថា សិទ្ធិរបស់ភាគី ត្រូវបានគោរពគ្រប់ពេល ក្នុងនោះមាន សិទ្ធិទទួលបានព័ត៌មានអំពីកិច្ចដំណើរការនីតិវិធីរបស់ភាគីដែលជាភាគីពាក់ព័ន្ធ។

6. អនុលោមតាមវិធានទាំងនេះ ចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិយល់ឃើញថា គាត់មានភារកិច្ចជូនដំណឹងដល់ភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ អំពីស្ថានការណ៍នៃភាពមិនអាចដំណើរការបានដែលប៉ះពាល់លើកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ និង អសមត្ថភាពទាំងស្រុងដែលគាត់ និងការិយាល័យរបស់គាត់កំពុងប្រឈម ហើយមិនអាចបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ ប្រកបដោយការខិតខំប្រឹងប្រែង ការយកចិត្តទុកដាក់ និងប្រសិទ្ធភាព បាននោះទេ។

7. មុននឹងបង្ហាញអំពីហេតុការណ៍ដែលបានលើកឡើងខាងលើ ចាំបាច់ត្រូវរឭកឡើងវិញថាចៅក្រមស៊ើបអង្កេត មិនអាចបង្ហាញការពិតអំពីការកើតឡើងនៃបទឧក្រិដ្ឋដែលត្រូវបានចោទ ឬថាតើបុគ្គលណាម្នាក់ទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋណាមួយឡើយ រហូតដល់កិច្ចស៊ើបសួរត្រឹមត្រូវ មិនលម្អៀង និងប្រកបដោយប្រសិទ្ធភាព ត្រូវបានបំពេញរួចរាល់អស់សិន។ វិសាលភាពនៃបទឧក្រិដ្ឋ ដែលបានកើតឡើង និងកម្រិតជាក់ស្ដែងនៃការចូលរួមរបស់បុគ្គលណាម្នាក់ដែលទទួលខុសត្រូវ មិនអាចកំណត់បានឡើយ ប្រសិនបើមិនមានការបំពេញកិច្ចស៊ើបសួរ ឱ្យបានពេញលេញនៅទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋ និងទីកន្លែងរបស់ជនសង្ស័យនោះទេ។

8. ការស៊ើបអង្កេតលើអង្គហេតុទាំងអស់ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត បន្ទាប់ពីទទួលបានការជូនដំណឹងអំពីបទឧក្រិដ្ឋមួយ ឬច្រើនជាងមួយភ្លាម។ "ដូចសហព្រះរាជអាជ្ញា បានរឭកដោយត្រឹមត្រូវថា យោងតាម

[3] វិធានផ្ទៃក្នុង ២១ (១)៖ គោលការណ៍ជាសារវ័ន្ត (គូសបញ្ជាក់បន្ថែម)

[4] វិធានផ្ទៃក្នុង ៥៥ (៥)៖ បទប្បញ្ញត្តិទូទៅទាក់ទងនឹងការស៊ើបសួរ (គូសបញ្ជាក់បន្ថែម)

វិធាន ៥៥ (២) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ក្នុងបញ្ហានេះ មានកាតព្វកិច្ចស៊ើបសួរគ្រប់អង្គហេតុទាំងអស់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (រួមទាំងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម) ដែលបានបញ្ជូនមកខ្លួន"។ [...] ម្យ៉ាងទៀត កាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត នៅដំណាក់កាលនៃការចេញដីកាដំណោះស្រាយ ក្នុងការសម្រេចលើគ្រប់អង្គហេតុទាំងអស់ ដែលបានស្នើឡើងត្រឹមត្រូវតាមច្បាប់ឱ្យបំពេញកិច្ចស៊ើបសួរ រួមបញ្ចូលផងដែរនូវកាតព្វកិច្ចបំពេញកិច្ចស៊ើបសួរលើគ្រប់អង្គហេតុទាំងអស់[5]។

9. ការរារាំងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងពីរនេះ ជាការរំលោភលើការអនុវត្តនីតិវិធីត្រឹមត្រូវតាមច្បាប់ និងដំណើរការល្អនៃកិច្ចការរដ្ឋបាលរបស់តុលាការ ដែលផ្ទុយពីអ្វីដែលភាគីក្នុងកិច្ចដំណើរការនីតិវិធី និងប្រជាជនកម្ពុជាជាទូទៅ មានសិទ្ធិទទួលបានពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## III. ហេតុការណ៍ដែលបានកើតឡើងចាប់តាំងពីការមកដល់របស់លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ

### ក. ការបដិសេធរបស់លោកចៅក្រមយូ ប៊ុនឡេង មិនទទួលស្គាល់ និងមិនគាំទ្រតួនាទីរបស់លោកចៅក្រម Laurent Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ

10. ការិយាល័យសហចៅក្រមស៊ើបអង្កេត មានចំនួនពីរក្រុមធ្វើការងារសហការគ្នា គឺក្រុមជាតិ និងក្រុមអន្តរជាតិ ដែលក្រុមនីមួយៗដឹកនាំដោយសហចៅក្រមស៊ើបអង្កេតមួយរូប។ លោកចៅក្រម Blunk ចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិរហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១។ គាត់បានដាក់ពាក្យលាលែងពីតំណែងនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ហើយការលាលែងពីតំណែងរបស់គាត់ចូលជាធរមាននៅចុងខែតុលា ឆ្នាំ ២០១១។ លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ដោយមានការអនុម័តពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជា

[5] ក.ស.ច.ស ដីកាសម្រេចលើសំណើសហព្រះរាជអាជ្ញាសុំការបំភ្លឺ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧ អ..វ.ត.ក-ក.ស.ច.ស ឯកសារ D198/1។

ណាចក្រកម្ពុជា និងបានស្បថចូលកាន់តំណែងនៅអំឡុងពេលកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១។ អាស្រ័យហេតុនេះ តាមផ្លូវច្បាប់ លោកចៅក្រម Laurent Kasper-Ansermet ដែលជាចៅក្រមបម្រុង ត្រូវចូលកាន់តំណែងជំនួសចៅក្រមដែលបានលាលែងតំណែង ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ មក។

11. នៅពេលលោកចៅក្រម Laurent Kasper-Ansermet មកដល់ទីក្រុងភ្នំពេញនៅដើមខែ ធ្នូ គាត់ចេញសេចក្តីប្រកាសព័ត៌មានមួយប្រកាសអំពីវត្តមានរបស់គាត់នៅអ.វ.ត.ក និងការប្តេជ្ញាចិត្តរបស់គាត់ "ចាត់ចែងធ្វើកិច្ចស៊ើបសួរ ព្រមទាំងចាត់រាល់វិធានការចាំបាច់នានាដើម្បីគ្រប់គ្រងការិយាល័យរបស់ខ្លួន"[6] ដែលជាតួនាទីរបស់គាត់ជាសហចៅក្រមស៊ើបអង្កេត។

12. ជាការឆ្លើយតប សហចៅក្រមស៊ើបអង្កេតជាតិ បានចេញសេចក្តីប្រកាសព័ត៌មានមួយដែរនៅថ្ងៃដដែលនោះ គឺថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ ជំទាស់នឹងតួនាទីរបស់លោកចៅក្រម Laurent Kasper-Ansermet។ គាត់បានថ្លែងថា រហូតមកដល់ពេលនេះ "មិនទាន់មានការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីជាផ្លូវការមកជំនួសនៅឡើយទេ" ហើយ "សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ត្រូវតែរង់ចាំទទួលបានការតែងតាំងជាផ្លូវការតាមនីតិវិធីជាធរមានជាមុនសិន មុននឹងចាប់ផ្តើមការងាររបស់ខ្លួន។ ដូច្នេះចំណាត់ការនិតិវិធីផ្សេងៗរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ លោកចៅក្រម Laurent Kasper-Ansermet មិនមានសុពលភាពតាមផ្លូវច្បាប់ឡើយ"[7]។

13. ចាប់ពីពេលនោះមក ផ្អែកលើសំអាងហេតុខាងលើនេះ លោកចៅក្រម យូ ប៊ុនឡេង បានជំទាស់ជាប្រព័ន្ធមិនប្រាស្រ័យទាក់ទងការងារណាមួយ ជាមួយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិឡើយ និងជំទាស់គ្រប់វិធានការដែលសមភាគីរបស់គាត់ មានព្យាយាមអនុវត្តដើម្បីបន្តកិច្ចស៊ើបសួរ[8]។ នៅក្នុងសេចក្តីប្រកាសព័ត៌មានមួយទៀត ចេញនៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតជាតិ បានប្រកាសថា "សហចៅក្រមស៊ើបអង្កេតជាតិ

---

[6] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត បម្រុង អន្តរជាតិ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១

[7] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១

[8] សូមមើលសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ Amnesty International "កម្ពុជា៖ តែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅសាលាក្តីខ្មែរក្រហមឱ្យបានឆាប់រហ័ស" ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២។

សូមបញ្ជាក់ជាថ្មីថា សហចៅក្រមជាតិ មិនដែលបានពិភាក្សាលើបញ្ហាកិច្ចនីតិវិធីណាមួយជាមួយចៅក្រម Laurent Kasper-Ansermet ឡើយ”[9]។

14. លោកចៅក្រមយូ ប៊ុនឡេង បានប្រាស្រ័យទាក់ទងការងារដោយផ្ទាល់ជាមួយសមភាគីអន្តរជាតិរបស់គាត់តែមួយលើកប៉ុណ្ណោះ ដើម្បីបញ្ជាក់ជាថ្មីថា លោកនឹងមិនប្រាស្រ័យទាក់ទងការងារ ឬសហការជាមួយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ តាមមធ្យាបាយណាក៏ដោយ។ តាមរយៈលិខិតមួយចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ ជាការឆ្លើយតបទៅនឹងសេចក្តីព្រៀងនៃដីកាមួយដែលត្រូវលើកយកមកពិភាក្សា និងស្នើសុំការព្រមព្រៀង លោកចៅក្រមយូ ប៊ុនឡេង បានសរសេរទៅកាន់លោកចៅក្រម Laurent Kasper-Ansermet ថា “ខ្ញុំសូមជម្រាបលោកចៅក្រមថា ខ្ញុំអាចពិភាក្សាអំពីខ្លឹមសារ នៃកិច្ចដំណើរការនីតិវិធីជាមួយលោកបាន លុះត្រាតែលោកទទួលបានការតែងតាំងជាផ្លូវការ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន[10]”។

15. ក្រោយមកទៀត លោកចៅក្រមយូ ប៊ុនឡេង បានជំទាស់ជាប្រព័ន្ធនឹងលិខិតទំនាក់ទំនងការងារទាំងអស់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ រួមមានសារអេឡិចត្រូនិក និងអនុស្សរណៈផ្ទៃក្នុង និងបានជំទាស់មិនទទួលយកការជូនដំណឹងអំពីឯកសារទាំងនោះ និងសេចក្តីសម្រេច ឬដីកា ចេញដោយលោកចៅក្រម Laurent Kasper-Ansermet ឡើយ។ វាជាការរំលោភលើច្បាប់ជាតិ និងច្បាប់អន្តរជាតិក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.កដែលលោកចៅក្រមយូប៊ុនឡេង សម្រេចច្រានចោលការប្រាស្រ័យទាក់ទងការងារទាំងអស់ និងមិនអើពើចំពោះការតែងតាំងលោកចៅក្រម Laurent Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ដោយមានការអនុម័តពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ។ ការតែងតាំងនោះ ផ្តល់តួនាទីឲ្យគាត់បំពេញការងារ និងភារកិច្ចជាសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងច្បាប់ និងកិច្ចព្រមព្រៀងស្តីពីការបង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុងក្នុងពេលអវត្តមានចៅក្រមពេញសិទ្ធិដែលបានលាលែងពីតំណែង។

---

[9] អនុស្សរណៈផ្ទៃក្នុងរបស់លោកចៅក្រមយូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ ផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១។

[10] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២។

16. លើសពីនេះ ការចូលរួមរបស់លោកចៅក្រមយូ ប៊ុនឡេង ក្នុងកិច្ចពិភាក្សាសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងការតែងតាំងលោកចៅក្រម Laurent Kasper-Ansermet បន្ទាប់ពីគាត់ចេញសេចក្តីថ្លែងការណ៍ម្តងហើយម្តងទៀតអំពីការប្រឆាំងរបស់គាត់ចំពោះការតែងតាំងនោះ បង្កើតឲ្យមានការសង្ស័យចំពោះភាពមិនលម្អៀងរបស់គាត់ក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ជាងនេះទៅទៀត ដូចអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានលើកឡើងអំពីប្រទេសកម្ពុជា ការមិនសម្រេចតែងតាំងសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ឲ្យកាន់តួនាទីពេញសិទ្ធិជាសហចៅក្រមស៊ើបអង្កេតនៅអ.វ.ត.ក "ជាការរំលោភលើមាត្រា ៥ កថាខណ្ឌ ៦ នៃកិច្ចព្រមព្រៀង[11]" ស្តីពីការបង្កើតអ.វ.ត.ក និងធ្វើឲ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅដោយសមស្របនៃតុលាការនេះ[12]។

17. មតិយោបល់របស់លោកចៅក្រម យូ ប៊ុនឡេង ទាក់ទងនឹងការតែងតាំងលោកចៅក្រម Laurent Kasper-Ansermet ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនមានមូលដ្ឋានគតិយុត្តិឡើយ។ ដូចបានលើកឡើងរួមមកហើយ លោកចៅក្រម Laurent Kasper-Ansermet ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ កាលពីខែ វិច្ឆិកា ឆ្នាំ ២០១០ នៅពេលដែលលោកចៅក្រម Blunk សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិនៅពេលនោះបានជំនួសលោកចៅក្រម Lamonde។ នៅពេលលោកចៅក្រម Blunk បានលាលែងចេញពីតំណែងក្នុងខែ តុលា ឆ្នាំ ២០១១ លោកចៅក្រម Laurent Kasper-Ansermet បានបំពេញតួនាទីនោះក្នុងតំណែងរបស់គាត់ជាចៅក្រមបម្រុង។ វាមិនចាំបាច់ក្នុងការតែងតាំងបន្ថែមសម្រាប់ឲ្យមន្ត្រីបម្រុងក្លាយជាមន្ត្រីពេញសិទ្ធិក្នុងករណីតំណែងនោះនៅទំនេរឡើយ។ លោកចៅក្រម Downing និងលោកចៅក្រម Chung ចៅក្រមអង្គបុរេជំនុំជម្រះនៃអ.វ.ត.ក "អ.ប.ជ" បានថ្លែងក្នុងមតិយោបល់ដោយឡែកចំនួនពីរថា ពួកគាត់ "ជំទាស់ទៅនឹងយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ត្រង់ចំណុចដែលថាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ពុំទាន់មានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការបំពេញ

---

[11] សេចក្តីថ្លែងការណ៍ព័ត៌មានរបស់អ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទាក់ទងនឹងប្រទេសកម្ពុជា ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ http://www.un.org/sg/statements/?nid=5815.

[12] សូមមើលផងដែរ OSJI "ការវិវឌ្ឍន៍ថ្មីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រទី ២០-៣០។

តួនាទីតាមនីតិវិធីច្បាប់ជាធរមាន"[13]។ លោកចៅក្រមទាំងពីររូប រំឭកឡើងវិញអំពីដំណើរការនីតិវិធីសមស្របដែលត្រូវអនុវត្តតាមក្នុងករណីតួនាទីនៅទំនេរ៖ "ក្រោយពេលអវត្តមានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ ហើយ*ក្នុងពេលទន្ទឹមនឹងនេះ* អនុលោមតាមច្បាប់ជាធរមាននៅអ.វ.ត.ក ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីតុលាការបន្តប្រព្រឹត្តដោយរលូន និងទាន់ពេលវេលា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងត្រូវបំពេញភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[14]"។ មិនមានទម្រង់ការបន្ថែមដែលចាំបាច់សម្រាប់ការជំនួសតំណែងនេះទេ៖ "បញ្ញត្តិទាំងនេះមានចែងនៅក្នុងច្បាប់ ប្រយោជន៍ដើម្បីធានាថា អវត្តមានរបស់ចៅក្រមណាម្នាក់នឹងពិតជាពុំប៉ះពាល់ ឬអូសបន្លាយកិច្ចដំណើរការនីតិវិធីឡើយ។ អត្ថិភាពនៃតួនាទីរបស់ចៅក្រមបម្រុងគឺដើម្បីការពារគោលបំណងនេះឯង[15]"។ ការជំទាស់ឥតឈប់ឈរ និងដោយសកម្មរបស់លោកចៅក្រមយូ ប៊ុនឡេង ចំពោះការជំនួសតំណែងជាចៅក្រមពេញសិទ្ធិដោយចៅក្រមបម្រុង ដែលមានលក្ខណៈសាមញ្ញ និងត្រឹមត្រូវតាមច្បាប់នៅអ.វ.ត.ក និងនៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីទាន់ពេលវេលានៅអ.វ.ត.ក និងសិទ្ធរបស់ភាគីទាំងអស់។

### ខ) កិច្ចដំណើរការនីតិវិធីនៃការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២

18. បន្ទាប់ពីបានបំពេញតួនាទីជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១១ មក លោកចៅក្រម Laurent Kasper-Ansermet បានវាយតម្លៃឡើងវិញអំពីស្ថានភាពនៃការស៊ើបអង្កេតក្នុងសំណុំរឿង០០៣[16] ហើយបន្ទាប់ពីបានរកឃើញថា "ការស៊ើបសួរដែលបានធ្វើកន្លងមក មកដល់ពេលនេះ ហាក់ដូចជាមានលក្ខណៈខ្វះចន្លោះ និងប៉ះពាល់ផលប្រយោជន៍របស់ភាគីទាំងអស់"[17] លោកចៅក្រម Laurent Kasper-Ansermet

---

[13] សំណុំរឿង០០៣/១៦-១២-២០១១-អ.វ.ត.ក/អ.ប.ជ យោបល់របស់ចៅក្រម Downing និងចៅក្រម Chung នៃអង្គបុរេជំនុំជម្រះស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន៧២នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣១។

[14] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៣

[15] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៤

[16] សំណុំរឿង០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ D28។

[17] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៨

បានសម្រេចពិចារណាឡើងវិញនូវសេចក្តីជូនដំណឹងនៃការបញ្ចប់កិច្ចស៊ើបសួរ និងចាប់ផ្តើមបំពេញកិច្ចស៊ើបសួរឡើងវិញ។ គាត់បានបញ្ជូនដីកាបំពេញកិច្ចស៊ើបសួរឡើងវិញជូនសមភាគីជាតិរបស់គាត់ដើម្បីស្នើសុំការព្រមព្រៀងនៅថ្ងៃដដែលនោះ ដោយសង្ឃឹមថា នឹងឈានទៅដល់ការព្រមព្រៀងគ្នាលើការបំពេញកិច្ចស៊ើបសួរក្នុងពេលអនាគត[18]។

19. លោកចៅក្រម យូ ប៊ុនឡេង បានឆ្លើយតបនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១[19] ដោយជម្រាបលោកចៅក្រម Laurent Kasper-Ansermet ថា យោងតាមមតិយោបល់របស់គាត់អំពីមុខតំណែងរបស់លោកចៅក្រម Laurent Kasper-Ansermet គាត់នឹងមិនពិភាក្សា "ខ្លឹមសារនៃកិច្ចដំណើរការនីតិវិធី"ជាមួយលោកចៅក្រម Laurent Kasper-Ansermet ឡើយ។

20. បន្ទាប់ពីកត់សម្គាល់អំពីការជំទាស់របស់គាត់ និងដោយហេតុថាគាត់មិនទទួលបានឯកសារទំនាក់ទំនាក់ការងារផ្សេងទៀតពីសហចៅក្រមស៊ើបអង្កេតជាតិទេនោះ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានធ្វើកំណត់ត្រានៃការខ្វែងយោបល់គ្នា[20] ដោយអនុលោមតាមនីតិវិធីនៃវិធាន ៧២ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ដែលចែងអំពីវិធីសាស្ត្រដោះស្រាយការខ្វែងយោបល់គ្នាបែបនោះ។ ឯកសារសំខាន់ទាំងអស់ ត្រូវបានផ្ញើជូនដោយសមស្រប និងទាន់ពេលវេលាដល់អង្គបុរេជំនុំជម្រះដើម្បីធ្វើការដោះស្រាយការខ្វែងយោបល់នេះ។

21. ទាក់ទិននឹងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសដោយផ្ទេរអំណាចស៊ើបអង្កេត និងបេសកកម្មឱ្យអ្នកស៊ើបអង្កេតនៃក.ស.ច.ស អនុលោមតាមច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុង[21]។ បន្ទាប់មកសហចៅក្រម

---

[18] លិខិតរបស់លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនលោកចៅក្រមយូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ គូសសម្គាល់ថា "បានទទួល" នៅម៉ោង ៣ នៅថ្ងៃដដែលនោះ ដោយលោក ហម ហែល ជំនួយការក្រឡាបញ្ជីជាតិរបស់ក.ស.ច.ស។

[19] អនុស្សរណៈផ្ទៃក្នុងរបស់លោកចៅក្រមយូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ ផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១។

[20] ក.ស.ច.ស កំណត់ត្រានៃការខ្វែងយោបល់គ្នា ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១។

[21] កំណត់ត្រានៃការខ្វែងយោបល់គ្នា ឯកសារភ្ជាប់ ៣.១ ដីកាចាត់ឱ្យស៊ើបសួរជំនួស។

ស៊ើបអង្កេត បានបញ្ជូន[22] ដីកាចាត់ឲ្យស៊ើបសួរជំនួសនោះជូនសមភាគីជាតិរបស់គាត់ដើម្បីឲ្យ "ពិនិត្យមើល និងស្នើសុំការព្រមព្រៀង"។

22. ដោយហេតុថា មិនមានការឆ្លើយតបពីសហចៅក្រមស៊ើបអង្កេតជាតិទាក់ទងនឹងដីកាចាត់ឲ្យស៊ើបជំនួសនេះ ចៅក្រមអន្តរជាតិ បានដាក់កំណត់ត្រានៃការខ្វែងគំនិតគ្នាដោយសមស្រប និងបានជូនដំណឹងដល់ការិយាល័យរដ្ឋបាល[២៣] ដើម្បីឲ្យអង្គបុរេជំនុំជម្រះទទួលយកបញ្ហានេះមកដោះស្រាយ ដោយអនុលោមតាមវិធាន៧២ ស្តីពីការដោះស្រាយការខ្វែងយោបល់គ្នានេះ។

23. អនុលោមតាមវិធាន ៧២ បន្ទាប់ពីទទួលបានកំណត់ត្រាស្តីពីការខ្វែងយោបល់គ្នាភ្លាម អង្គបុរេជំនុំជម្រះ ត្រូវអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតដាក់ឯកសារឆ្លើយតប [(វិធាន ៧២ (២)] រៀបចំធ្វើសវនាការ [(វិធាន ៧២ (៤) (ក)] ហើយក្នុងករណីខ្លះ ភាគីក្នុងកិច្ចដំណើរការនីតិវិធី [(វិធាន ៧២ (៤) (ខ)] និងអ្នកជំនាញ [(វិធាន ៧២ (៤) (គ)] អាចចូលរួម។ វិធាន ៧២ ចែងអំពីទម្រង់ការនីតិវិធីដែលត្រូវគោរពសម្រាប់ការដោះស្រាយតាមផ្លូវច្បាប់នូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត។ នៅពេលបញ្ចប់នីតិវិធីនេះ អង្គបុរេជំនុំជម្រះ ចេញសេចក្តីសម្រេច ដែលមានសំអាងសមស្រប និងចុះហត្ថលេខាដោយចៅក្រម និងការសំដែងមតិយោបល់ជំទាស់ [(វិធាន ៧២ (៤) (ឃ) និង (វិធាន ៧២ (៤) (ង)] ។

24. វាជាការរំលោភទាំងស្រុងលើវិធានដែលបានលើកឡើងខាងលើនេះ ដែលលោកចៅក្រមប្រាក់ គីមសាន ប្រធានអង្គបុរេជំនុំជម្រះ បានបញ្ជូនឯកសារដែលបានដាក់រួចហើយត្រឡប់មកការិយាល័យរដ្ឋបាលវិញកាលពីថ្ងៃទី ០៣ ខែ កុម្ភៈឆ្នាំ ២០១២ ដោយជូនដំណឹងប្រធានរដ្ឋបាលស្តីទីថា ការខ្វែងយោបល់គ្នាទាំងពីរនេះ ត្រូវបានពិភាក្សាហើយក្នុងអង្គជំនុំជម្រះ

---

[22] ក.ស.ច.ស លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូន ចៅក្រមយូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ "សំណុំរឿង០០៤/ដីកាចាត់ឲ្យស៊ើបសួរជំនួស" ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១១។ សូមមើល កំណត់ត្រានៃការខ្វែងយោបល់គ្នា ឯកសារភ្ជាប់ ៣.១។

[23] ក.ស.ច.ស កំណត់ត្រានៃការខ្វែងយោបល់គ្នា ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ "អនុស្សរណៈផ្ទៃក្នុងរបស់លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូនលោកក្រាញ់ តូនី និងលោក Knut Rosandhaug ការិយាល័យរដ្ឋបាល "Transmission des documents de désaccord entre les Co-juges d'instruction" ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២។

កាលពីថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ប៉ុន្តែ "អ.ប.ជ មិនឈានទៅដល់ព្រមព្រៀងគ្នាដើម្បីយកខ្លឹមសារនៃឯកសារនោះមកពិចារណាឡើយ" ដោយហេតុថា "លោកចៅក្រម Laurent Kasper-Ansermet មិនមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចរបស់គាត់យោងតាមនីតិវិធីច្បាប់ជាធរមានឡើយ"[24]។

25. ទោះជាយ៉ាងណា ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានលើកឡើងពីការខ្វែងយោបល់របស់ពួកគាត់ក្នុងមតិយោបល់ជំទាស់អំពីនីតិវិធីមិនសមស្រប ដែលអនុវត្តដោយប្រធានអង្គបុរេជំនុំជម្រះ[25]។ ពួកគាត់រំឭកឡើងវិញនូវកាតព្វកិច្ចដែលអង្គបុរេជំនុំជម្រះត្រូវអនុវត្តអនុលោមតាមវិធានផ្ទៃក្នុង ក្នុងការចេញសេចក្តីសម្រេចដែលមានសំអាងហេតុសមស្រប និងត្រឹមត្រូវតាមផ្លូវច្បាប់៖ "ឯកសារប្រភេទនេះពុំអាចត្រូវបានប្រគល់ត្រឡប់ទៅការិយាល័យរដ្ឋបាលក្នុងលក្ខណៈជាចំណាត់ការរដ្ឋបាលបានឡើយ"។ ចំពោះកម្មវត្ថុដែលត្រូវលើកយកមកដោះស្រាយ ចៅក្រមអន្តរជាតិទាំងពីររូប គាំទ្រទស្សនៈរបស់លោកចៅក្រម Laurent Kasper-Ansermet ដែលថា "នៅពេលដែលសហចៅក្រមស៊ើបអង្កេតអវត្តមាន រួមទាំងនៅក្នុងករណីដែលចៅក្រមលាឈប់ពីតួនាទី សហចៅក្រមស៊ើបអង្កេតបម្រុងអាចបន្តបំពេញការងារប្រចាំថ្ងៃរបស់សហចៅក្រមស៊ើបអង្កេត ដែលអវត្តមាននោះ"[26]។

26. បន្ទាប់ពីបានកត់សម្គាល់អំពីមោឃភាព ចំពោះការមិនគោរពវិធានបញ្ញត្តិក្នុងការឆ្លើយតបរបស់លោកចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ចំពោះការខ្វែងយោបល់គ្នាទាំងពីរដែលបានដាក់ឲ្យអង្គបុរេជំនុំជម្រះដោះស្រាយ សហចៅក្រមស៊ើបអង្កេតបម្រុង

---

[24] អនុស្សរណៈអន្តរការិយាល័យរបស់លោកចៅក្រម ប្រាក់ គឹមសាន ផ្ញើជូនលោកក្រាញ់តូនី ប្រធានការិយាល័យរដ្ឋបាល ស្តីទីក្រោមកម្មវត្ថុ "បញ្ជូនត្រឡប់វិញនូវសំណុំឯកសារដែលការិយាល័យរដ្ឋបាលផ្ញើជូនអង្គបុរេជំនុំជម្រះ" ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

[25] សំណុំរឿង០០៣/១៦-១២-២០១១-អ.វ.ត.ក/អ.ប.ជ មតិយោបល់របស់ចៅក្រម Downing និងចៅក្រម Chung នៃអង្គ បុរេជំនុំជម្រះស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន៧២នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៤-១៦។ សំណុំរឿង០០៤/១៩-០១-២០១២-អ.វ.ត.ក/អ.ប.ជ មតិយោបល់របស់ចៅក្រម Downing និងចៅក្រម Chung នៃអង្គបុរេជំនុំជម្រះស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន៧២នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១២-១៤។

[26] មតិយោបល់ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣៤, មតិយោបល់ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣២។

អន្តរជាតិ បានបញ្ជូនកំណត់ត្រានៃការខ្វែងយោបល់គ្នាត្រឡប់ទៅអង្គបុរេជំនុំជម្រះវិញ ដើម្បីឱ្យអង្គបុរេជំនុំជម្រះដោះស្រាយមោឃភាពចំពោះការមិនគោរពវិធានបញ្ញត្តិនោះ[27]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ត្រូវបានផ្តល់ជូន*ការទទួលស្គាល់នៃការជូនដំណឹង* ពីក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ដោយបញ្ជាក់ថាគាត់ "មិនទទួលយកឡើយ។ អ្នកដាក់ឯកសារមិនសិទ្ធិអំណាចតាមផ្លូវច្បាប់ឡើយ"[28]។

27. សំអាងហេតុដែលផ្តល់ដោយប្រធាន និងក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ក្នុងការជំទាស់ការដាក់កំណត់ត្រានៃការខ្វែងយោបល់គ្នាទាំងនេះម្តងហើយម្តងទៀត ទំនងជាផ្តើមចេញពីការច្រានចោលតួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិរបស់លោកចៅក្រម Laurent Kasper-Ansermet ដែលបានលើកឡើងដោយលោកចៅក្រម យូ ប៊ុនឡេង នៅក្នុងការប្រាស្រ័យទាក់ទងការងារគ្រប់ពេលរបស់គាត់ ឬអ្នកនៅក្រោមបង្គាប់គាត់។

## គ) ភាពមិនប្រក្រតីនៅក្នុងដំណើរការដោះស្រាយបណ្តឹងមិតចិត្តលោកចៅក្រម ប្រាក់ គឹម សាន

28. ដោយបានឃើញថា ពុំមានដំណើរការឱ្យបានត្រឹមត្រូវនៅក្នុងនីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា និងភាពលម្អៀងជាក់ស្តែងរបស់លោកចៅក្រម ប្រាក់ គឹមសាន ជាប្រធានអង្គបុរេជំនុំជម្រះ និងជាអ្នកសរសេរសេចក្តីសម្រេចបញ្ជូនសំណើត្រឡប់ទៅវិញដោយពុំបានផ្តល់សេចក្តីពិចារណាដែលមានសំអាងហេតុនោះ លោកចៅក្រម Kasper-Ansermet បានចាត់វិធានការចាំបាច់ អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងបានប្តឹងមិតចិត្តលោកចៅក្រម ប្រាក់ គឹមសាន[29]។

---

27 អនុស្សរណៈអន្តរការិយាល័យរបស់លោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូនលោកចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ "ការដោះស្រាយការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេត" ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២។

28 ការទទួលស្គាល់នៃការជូនដំណឹង ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ចុះហត្ថលេខាដោយលោកគឹម សាន មន្ត្រីការិយាល័យរដ្ឋបាល និងចំណាររបស់លោកពីលោក គង់ តារានាត ក្រឡាបញ្ជីអ.ប.ជ។

29 ពាក្យបណ្តឹងមិតចិត្តលោកចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៣៤(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

29. នៅពេលលោកចៅក្រម ប្រាក់ គឹមសាន បញ្ជូនត្រឡប់ទៅវិញ ដោយមិនអនុលោមតាមនីតិវិធីសមរម្យ នូវឯកសារនានាដែលពាក់ព័ន្ធនឹងសំណើសុំដោះស្រាយការខ្វែងយោបល់គ្នាដែលសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានផ្ញើជូនការិយាល័យរដ្ឋបាលនោះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសំដែងការមិនយល់ស្របទៅនឹងវិធានការខុសប្រក្រតីបែបនេះ។ នៅថ្ងៃដដែលនោះ ចៅក្រមទាំងនេះបានសសេរអនុស្សរណៈមួយច្បាប់ផ្ញើជូនប្រធានស្តីទីការិយាល័យរដ្ឋបាល[30] "ដោយជូនដំណឹងថា អនុស្សរណៈដែលបានចុះហត្ថលេខាដោយប្រធានអង្គបុរេជំនុំជម្រះក្នុងការបញ្ជូនត្រឡប់មកវិញ នូវឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នាត្រូវបានចេញ មុនជូនដំណឹងទៅចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ហើយថាអង្គបុរេជំនុំជម្រះពុំទាន់បានពិភាក្សាសម្រេចចប់សព្វគ្រប់នៅឡើយទេ។ អនុស្សរណៈនេះក៏បានកត់សម្គាល់ផងដែរថា លិខិតប្រាស្រ័យទាក់ទងការងារដែលចេញដោយលោកចៅក្រម ប្រាក់ គឹមសាន ពុំតំណាងឲ្យមតិ ឬសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំងមូលទេ"[31]។ ហេតុនេះ លិខិតនេះ "ពុំមានអានុភាពតាមផ្លូវច្បាប់ទៅលើលទ្ធផលនៃករណីខ្វែងយោបល់គ្នាទាំងនេះទេ"។

30. ទាក់ទិននឹងពាក្យបណ្តឹងមិតចិត្តលោកចៅក្រម ប្រាក់ គឹមសាន និងដោយពិចារណាពីការចូលរួមរបស់ខ្លួនទៅក្នុងកិច្ចដំណើរការនីតិវិធីដែលនាំឲ្យមានសំណើនេះវិញ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានពិចារណាឃើញថា វាជាតួនាទីរបស់ខ្លួនអនុលោមតាមវិធាន ៣៤(១) ក្នុងការដកខ្លួនចេញពីកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងការពិនិត្យទៅលើសំណើនោះ ឬ

---

[30] អនុស្សរណៈអន្តរការិយាល័យ (សម្ងាត់) ចៅក្រម Rowan Downing និង ចៅក្រម Chang-Ho Chung ជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ផ្ញើជូន ឯកឧត្តម ក្រាញ់ តូនី ប្រធានស្តីពីការិយាល័យរដ្ឋបាល "អនុស្សរណៈថ្ងៃនេះពីលោកចៅក្រម ប្រាក់ គឹមសាន ដែលបានចុះហត្ថលេខាក្នុងឋានៈជាប្រធានអង្គបុរេជំនុំជម្រះផ្ញើជូនដោយផ្ទាល់ជូនឯកឧត្តមតាមកម្មវត្ថុ៖ ការផ្ញើត្រឡប់មកវិញនូវឯកសារប្រាស្រ័យទាក់ទងការងារជាមួយអង្គបុរេជំនុំជម្រះ ដោយការិយាល័យរដ្ឋបាល" ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

[31] សំណុំរឿងលេខ ០០៣/១៦-១២-២០១១-អ.វ.ត.ក/អ.ប.ជ, យោបល់របស់លោកចៅក្រម Downing និង លោកចៅក្រម Chung ជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះទៅលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៧២, ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ១៤; សូមមើលផងដែរ សំណុំរឿងលេខ ០០៤/១៩-០១-២០១២-អ.វ.ត.ក/អ.ប.ជ យោបល់របស់លោកចៅក្រម Downing និង លោកចៅក្រម Chung ជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះទៅលើការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៧២, ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

រាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសំណើនោះ។ ពួកគេមានការព្រួយបារម្ភថា បើតាមផ្លូវច្បាប់ ការជំទាស់ជាសាធារណៈចំពោះសកម្មភាពរបស់លោកចៅក្រម ប្រាក់ គឹមសាន ពួកគេបានប្រកាន់យកជំហរដែលអាច "នាំឱ្យលេចឡើងនូវការលម្អៀងជាសត្យានុម័ត"។

31. វិធាន ៣៤(៦) ចែងថា ក្នុងករណីបែបនេះ "ចៅក្រមពេញសិទ្ធិ អាចត្រូវជំនួសចៅក្រមបម្រុងនៃអង្គជំនុំជម្រះនោះបាន សម្រាប់តែករណីនៃបណ្តឹងជិតចិត្តនោះប៉ុណ្ណោះ។ ប្រសិនបើមានពាក្យបណ្តឹងជិតចិត្ត ដែលមិនអាចរៀបចំអង្គជំនុំជម្រះ ដើម្បីសម្រេចលើពាក្យបណ្តឹងទាំងនោះបានទេ គណៈកម្មាធិការរដ្ឋបាលតុលាការត្រូវជ្រើសរើសចៅក្រមបន្ថែមពីក្នុងចំណោមចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

32. អាស្រ័យហេតុនេះចៅក្រម ៣ រូបក្នុងចំណោមចៅក្រមទាំង ៥ រូបនៃអង្គបុរេជំនុំជម្រះមិនអាចចូលរួមក្នុងការពិនិត្យពិចារណាទៅលើពាក្យបណ្តឹងជិតចិត្តលោកចៅក្រម ប្រាក់ គឹមសាន បានទេ រួមមាន៖ លោកចៅក្រម ប្រាក់ គឹមសាន និងចៅក្រមអន្តរជាតិ ២ រូបដែលបានសម្រេចដកខ្លួននោះ។ មានតែលោកចៅក្រម ន័យ ថុល និងលោកចៅក្រម ហ៊្វូត វុទ្ធី ទើបនៅជាចៅក្រមពេញសិទ្ធិ តែប្រការនេះ "មិនអាចកោះប្រជុំអង្គជំនុំជម្រះបានទេ" ហើយចាំបាច់ត្រូវតែងតាំងចៅក្រមបន្ថែមសម្រាប់ដំណើរការនីតិវិធីទៅមុខបាន។ ទោះជាយ៉ាងណាក្តី នៅពេលបានទទួលព័ត៌មានស្តីពីបញ្ហានេះនៅថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២[32] មកដល់ពេលនេះ គណៈកម្មាធិការរដ្ឋបាលតុលាការនៅ អ.វ.ត.ក មិនទាន់បានកោះប្រជុំដើម្បីសម្រេចចំពោះការតែងតាំងចៅក្រម ឬមិនទាន់បានថ្លែងអះអាងតាមវិធីណាមួយបញ្ជាក់ពីចេតនារបស់ខ្លួនក្នុងការតែងតាំងចៅក្រមនាពេលអនាគតដ៏ខ្លីនោះទេ។ ប្រការគួរឱ្យកត់សម្គាល់គឺថា អនុលោមតាមវិធាន ១៩ គណៈកម្មាធិការនោះ "រួមមានចៅក្រមជាតិ ៣ រូប ដែលមានមួយរូបជាប្រធាន និងចៅក្រមអន្តរជាតិ ២ រូប"៖ គេអាចសន្និដ្ឋានបានថា ផ្នែកជាតិ/អន្តរជាតិ ដែលជះឥទ្ធិពលទៅលើបុគ្គលិកគ្រប់ផ្នែកនៅ អ.វ.ត.ក កំពុងមានអាទិភាពស្មើគ្នាទៅលើដំណើរការការងារ និងកិច្ចការរដ្ឋបាលតុលាការត្រឹមត្រូវ នៅក្នុងគណៈកម្មាធិការរដ្ឋបាលតុលាការ។

---

[32] សេចក្តីថ្លែងការណ៍ជាសាធារណៈដោយលោកចៅក្រម Downing និងលោកចៅក្រម Chung ជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។

## ឃ) ការបដិសេធមិនបញ្ចូលឯកសារទាំងឡាយដែលបានដាក់ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិទៅក្នុងសំណុំរឿង

33. នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានចុះហត្ថលេខាលើដីកាសម្រេចឱ្យបន្តកិច្ចស៊ើបសួរ បន្ទាប់ពីការបញ្ចប់ការដោះស្រាយនីតិវិធីនៃការខ្វែងយោបល់ ដែលបានស្នើឡើងដោយចៅក្រមរូបនេះនៅខែ ធ្នូ ឆ្នាំ ២០១១។ ក្រឡាបញ្ជីអន្តរជាតិនៃ ក.ស.ច.ស បានយកឯកសារដើមនៃឯកសារនេះ ផ្ញើទៅមន្ត្រីគ្រប់គ្រងសំណុំរឿង ដើម្បីបញ្ចូលទៅក្នុងសំណុំរឿង និងជូនដំណឹងទៅភាគី។

34. បន្ទាប់ពីបានពិនិត្យទៅលើដីកានោះ មន្ត្រីគ្រប់គ្រងសំណុំរឿងបានបដិសេធមិនទទួលយក ដោយសំអាងថា សហចៅក្រមស៊ើបអង្កេតជាតិមិនយល់ស្របឱ្យបញ្ចូលទៅក្នុងសំណុំរឿងទេ។ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានជួបមន្ត្រីគ្រប់គ្រងសំណុំរឿងដោយផ្ទាល់ ហើយបានពន្យល់គាត់ថា នីតិវិធីដោះស្រាយការខ្វែងយោបល់គ្នាបានធ្វើរួចហើយ ហើយថា អនុលោមតាមវិធានជាធរមាន[33] មន្ត្រីគ្រប់គ្រងសំណុំរឿងមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការជួយគាត់បញ្ចូលដីកាទៅក្នុងសំណុំរឿង។ មន្ត្រីគ្រប់គ្រងសំណុំរឿងបដិសេធមិនព្រមអនុវត្តតាមការណែនាំដោយផ្ទាល់មាត់ពីសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ និងបានស្នើសុំការណែនាំពីលោកចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ ប្រធានផ្នែកគ្រប់គ្រងតុលាការ រួមទាំងប្រធានក្រុមអ្នកច្បាប់ជាតិនៅ ក.ស.ច.ស ទៀតផង[34]។ ប្រធានផ្នែកគ្រប់គ្រងតុលាការបានបដិសេធ ដោយផ្ទាល់មាត់មិនព្រមបញ្ចូលដីកានោះទៅក្នុងសំណុំរឿង។ ចំណែកប្រធានក្រុមអ្នកច្បាប់ជាតិរបស់ក.ស.ច.សវិញ គាត់បានឆ្លើយតបនៅក្នុងសារអេឡិចត្រូនិកមួយដែលសរសេរថា "*លោកចៅក្រម យូ ប៊ុនឡេង ណែនាំ* [គាត់] ឱ្យឆ្លើយតបទៅនឹង [មន្ត្រីគ្រប់គ្រងសំណុំរឿង] វិញថា ការបញ្ចូលឯកសារណាមួយទៅក្នុងសំណុំរឿងតម្រូវឱ្យមានការឯកភាពពីចៅក្រមទាំងពីររូប។ ក្នុងស្ថានភាពបច្ចុប្បន្ននេះ ការិយាល័យសហចៅក្រម

---

[33] វិធាន ៩ នៃវិធានផ្ទៃក្នុង (មុខងាររបស់ការិយាល័យរដ្ឋបាល), វិធាន ៧២(៤)(ឃ) (ដំណោះស្រាយករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត)។

[34] សារអេឡិចត្រូនិកពីលោក សាន់ រ៉ាដា ផ្ញើជូនលោកចៅក្រម យូ ប៊ុនឡេង (ចម្លងជូន៖ លោក នួន ផារ័ត្ន, លោក គង់ សុភី, លោក ក្រាញ់ តូនី, លោក លី ច័ន្ទតុលា, លោកចៅក្រម Laurent Kasper-Ansermet) "សំណើសុំយោបល់" ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

ស៊ើបអង្កេតមិនអាចបញ្ចូលឯកសារណាមួយ ទៅក្នុងសំណុំរឿងបានទេ ដោយសារសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិមិនបានពិភាក្សា ឬសម្រេចលើបញ្ហានេះជាមួយលោកចៅក្រម យូ ប៊ុនឡេង ទេ”[35]។ បន្ទាប់មក មន្ត្រីគ្រប់គ្រងសំណុំរឿងបានអះអាងសាជាថ្មីពីការបដិសេធមិនព្រមបញ្ចូលដីកាសម្រេចបន្តកិច្ចស៊ើបសួរ *“ដោយផ្អែកលើការណែនាំពីលោកចៅក្រម យូ ប៊ុនឡេង”*[36]។

35. តាមការទទួលស្គាល់របស់ខ្លួន មន្ត្រីជាតិទាំងអស់ដែលបានដកស្រង់នៅក្នុងកថាខណ្ឌខាងលើបំពេញការងារតាមការណែនាំរបស់លោកចៅក្រម យូ ប៊ុនឡេង ដើម្បីជ្រៀតជ្រែកក្នុងការអនុវត្តសេចក្តីសម្រេចរបស់លោកចៅក្រម Kasper-Ansermet ទោះបីបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិធានផ្ទៃក្នុងមានចែងឲ្យចាត់វិធានការបែបនេះក៏ដោយ។

36. ការរារាំងដល់ការបញ្ចូលឯកសារទៅក្នុងសំណុំរឿងឲ្យបានត្រឹមត្រូវនេះមិនកំហិតត្រឹមតែដីកាសម្រេចបន្តកិច្ចស៊ើបសួរប៉ុណ្ណោះទេ តែក៏រាប់បញ្ចូលទាំងឯកសារទាំងអស់ដែលបានដាក់ដោយលោកចៅក្រម Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចាប់តាំងពីពេលដែលគាត់មកដល់ ដូចដែលមន្ត្រីគ្រប់គ្រងអង្គភាពបណ្ណសារនៃ អ.វ.ត.ក បានទទួលស្គាល់កាលពីថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២[37] ទោះបីឯកសារទាំងនោះមានសំអាងហេតុតាមផ្លូវច្បាប់ក៏ដោយ។

---

[35] សារអេឡិចត្រូនិកពីលោក នួន ផារ័ត្ន ផ្ញើជូនលោក សាន់ រ៉ាដា និងលោកចៅក្រម យូ ប៊ុនឡេង (ចម្លងជូន៖ លោក គង់ សុភី, លោក ក្រាញ់ តូនី, លោក លី ច័ន្ទតុលា, លោកចៅក្រម Laurent Kasper-Ansermet, លោក Knut Rosandhaug, លោក សោម រតនា) “យោង៖ សំណើសុំយោបល់” ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (គូសបញ្ជាក់បន្ថែម)។

[36] សារអេឡិចត្រូនិកពីលោក សាន់ រ៉ាដា ផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet (ចម្លងជូន៖ លោក គង់ សុភី, លោក ក្រាញ់ តូនី, លោក លី ច័ន្ទតុលា, លោក Knut Rosandhaug, លោក សោម រតនា, លោកចៅក្រម យូ ប៊ុនឡេង) “យោង៖ សំណើសុំយោបល់” ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ (គូសបញ្ជាក់បន្ថែម)។

[37] សារអេឡិចត្រូនិកពីលោក ពាង តុលា (ផ្នែកគ្រប់គ្រងតុលាការ, អង្គភាពបណ្ណសារ) ផ្ញើជូនអ្នកស្រី ឆាយ ច័ន្ទលីដា (ក.ស.ច.ស, ជំនួយការក្រឡាបញ្ជីអន្តរជាតិ) “យោង៖ ឯកសារក្នុងសំណុំរឿង ០០៣” ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២ នៅវេលាម៉ោង ២:២៩ រសៀល។

37. តាមរយៈការស៊ើបសួរពីមូលហេតុដែលនាំឱ្យមានភាពអសកម្មក្នុងការងារបែបនេះ ក្រឡាបញ្ជីអន្តរជាតិនៃ ក.ស.ច.ស បានទទួលព័ត៌មានកាលពីថ្ងៃទី ១១ ខែ មីនា ថា អនុប្រធានការិយាល័យរដ្ឋបាលបានសម្រេចដោះស្រាយបញ្ហានេះ ដោយបញ្ចូលសំណៅអេឡិចត្រូនិកទៅក្នុងថតផ្ទុកឯកសារ ក.ស.ច.ស។ វិធានការនេះមិនបានដោះស្រាយបញ្ហានេះទេ ដោយសារវាមិនបានឆ្លើយតបទៅនឹងមូលហេតុនៃបញ្ហា នោះគឺការណ៍ដែលបុគ្គលិកជាតិទាំងអស់បដិសេធមិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់លោកចៅក្រម Kasper-Ansermet និងមិនបានអនុញ្ញាតឱ្យសមាជិក ក.ស.ច.ស អាចបំពេញការងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព និងទៅតាមកាតព្វកិច្ចរបស់ខ្លួន ដែលតាមផ្លូវច្បាប់ ពួកគេត្រូវចូលប្រើប្រាស់សំណុំរឿងអេឡិចត្រូនិកបាន។ ជាងនេះទៀត ការបញ្ចូលឯកសារទៅក្នុងថតផ្ទុកឯកសារ ក.ស.ច.ស ពុំអនុញ្ញាតឱ្យភាគីដទៃទៀតដែលចូលប្រើប្រាស់សំណុំរឿងដូចជា សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនទាក់ទិននឹងបញ្ហានេះទេ[38]។ ការិយាល័យរដ្ឋបាលទទួលខុសត្រូវ គាំទ្រសហចៅក្រមស៊ើបអង្កេតក្នុងការបំពេញមុខងាររបស់ខ្លួន និងត្រូវទទួលខុសត្រូវក្នុងការបម្រើកិច្ចការរដ្ឋបាល និងផ្តល់សេវា [វិធាន ៩(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក] រួមទាំងការទទួលខុសត្រូវក្នុងការថែរក្សា ការតម្កល់ទុក និងការរក្សាសុវត្ថិភាពនៃភស្តុតាង រួមទាំងវត្ថុតាង ចម្លើយ និងឯកសារនានាដែលបានទទួលក្នុងពេលបំពេញកិច្ចស៊ើបសួរ [វិធាន ៩(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក]។

38. ជាការឆ្លើយតបវិញ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានសុំឱ្យមានការតែងតាំងមន្ត្រីគ្រប់គ្រងសំណុំរឿងអន្តរជាតិសម្រាប់រយៈពេលមួយសមរម្យ ដើម្បីធានានូវអព្យាក្រឹតភាព និងភាពមិនលម្អៀងនៃការិយាល័យរដ្ឋបាល[39]។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ក.ស.ច.ស បានទទួលព័ត៌មានថា មន្ត្រីច្បាប់នៃផ្នែកគ្រប់គ្រងតុលាការ "បានបំពេញតួនាទីជា

---

[38] វិធាន ៥៥(៦) និង ៥៥(១១) នៃវិធានផ្ទៃក្នុង ដែលវិធាន ៥៥(១១) អនុញ្ញាតឱ្យសហព្រះរាជអាជ្ញា និងមេធាវីតំណាងភាគីដទៃទៀតអាចពិភាក្សាជាមួយសំណុំរឿង*ដើម*បាន។

[39] អនុស្សរណៈអន្តរការិយាល័យពីលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល "ការតែងតាំងមន្ត្រីគ្រប់គ្រងសំណុំរឿងអន្តរជាតិ" ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២។

មន្ត្រីគ្រប់គ្រងសំណុំរឿងអន្តរជាតិ ដោយសារវាជាផ្នែកមួយនៃលក្ខន្តិកៈការងាររបស់ខ្លួន"[40]។ ទោះជាយ៉ាងណាក្តី តាមរយៈការផ្ទៀងផ្ទាត់បញ្ជាក់ដោយផ្ទាល់ពីសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ មន្ត្រីច្បាប់រូបនេះបានអះអាងថា មកទល់នឹងពេលនោះ ខ្លួនមិនទាន់បានទទួលនូវមធ្យោបាយណាមួយ ដើម្បីបំពេញការងារថ្មីទាំងនេះទេ រួមទាំងការបំពេញការងារក្នុងការិយាល័យរួមគ្នាជាមួយមន្ត្រីគ្រប់គ្រងសំណុំរឿងជាតិ។

**ង) ការបដិសេធមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចចូលប្រើប្រាស់សំណុំរឿង បន្ទាប់ពីមានដីកាអនុញ្ញាតស្តីពីភាពអាចទទួលយកបាន**

39. ស្រដៀងគ្នានេះដែរ សេចក្តីសម្រេចដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់របស់លោកចៅក្រម Kasper-Ansermet ត្រូវបានរារាំងដោយបុគ្គលិកជាតិនៅផ្នែកគ្រប់គ្រងតុលាការ រួមទាំងមន្ត្រីគ្រប់គ្រងសំណុំរឿង និងប្រធានផ្នែកនេះផងដែរ។ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ក.ស.ច.ស បានចេញដីកាមួយ[41] ដែលពិចារណាសាជាថ្មីឡើងវិញ ចំពោះសេចក្តីសម្រេចពីមុន ទៅលើភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ដោយផ្តល់ឱ្យគាត់នូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងអនុញ្ញាតឱ្យគាត់ចូលប្រើប្រាស់សំណុំរឿងនៃកិច្ចស៊ើបសួរ ដូចមានចែងក្នុងវិធាន ៥៥(៦) និង ៥៥(១១) នៃវិធានផ្ទៃក្នុង។ ទោះជាយ៉ាងណាក្តី បុគ្គលិកអន្តរជាតិនៅ ក.ស.ច.ស មានការចាប់អារម្មណ៍ថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចចូលប្រើប្រាស់សំណុំរឿង ០០៣ បាន។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានស្នើសុំឱ្យប្រធានក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស "ចាត់វិធានការចាំបាច់ នៅចំពោះមុខការិយាល័យរដ្ឋបាល ដើម្បី

---

[40] អនុស្សរណៈអន្តរការិយាល័យពីលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាលផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ "ការតែងតាំងមន្ត្រីគ្រប់គ្រងសំណុំរឿងអន្តរជាតិ" ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២។

[41] ដីកាសម្រេចស្តីពីការពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក Robert Hamill ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ឯកសារលេខ D11/2/5/1។

អនុវត្តសេចក្តីសម្រេចរបស់ចៅក្រម"[42] ហើយមន្ត្រីរូបនេះក៏បានទៅសាកសួរព័ត៌មានពីការិយាល័យរដ្ឋបាល។

40. នៅការិយាល័យរដ្ឋបាល ប្រធានក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស បានទទួលព័ត៌មានថា មន្ត្រីគ្រប់គ្រងសំណុំរឿងបានផ្តល់ការណែនាំមិនអនុញ្ញាតឱ្យមេធាវីតំណាងលោក Hamill អាចចូលប្រើប្រាស់សំណុំរឿងទេ ទោះបីសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានស្នើសុំបែបនេះក៏ដោយ។ ការខ្វែងយោបល់គ្នាទាក់ទិននឹងស្ថានភាពនេះបានបញ្ចប់ទៅ ដោយប្រធានក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស ត្រូវបានហាមឃាត់មិនឱ្យទំនាក់ទំនងជាមួយអង្គភាពបណ្ណសារ ពីសំណាក់ប្រធានផ្នែកគ្រប់គ្រងតុលាការ ដែលបានអំពាវនាវឱ្យមាន "ភាពជាវិជ្ជាជីវៈ និងស្មារតីក្រុមការងារ" ជាមូលហេតុក្នុងការសម្រេចបែបនេះ[43]។ ទោះជាយ៉ាងណាក្តី នាពេលបន្ទាប់មកទៀត ក្នុងថ្ងៃដដែលនោះ មន្ត្រីអន្តរជាតិនៃផ្នែកដដែលនេះបានអនុវត្តតាមសេចក្តីសម្រេចរបស់លោកចៅក្រម Kasper-Ansermet និងបានអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចប្រើប្រាស់សំណុំរឿង ០០៣ ប្រកបដោយប្រសិទ្ធភាព ដោយសន្និដ្ឋានថា អនុលោមទៅតាមនីតិវិធីជាធរមាន។

## ច) ការដកហូតត្រា ក.ស.ច.ស

41. អនុលោមតាមវិធាន ១(២) នៃវិធានផ្ទៃក្នុងចែងថា "ជាពិសេសលើកលែងតែមានចែងផ្សេងពីនេះ ការយោងទៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង"។ វិធាននេះ

[42] Ignacio Tredici ប្រធានក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស, កំណត់សម្គាល់ជូនចំពោះសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ, ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១២។

[43] សារអេឡិចត្រូនិកពីលោក គង់ សុភី ប្រធានផ្នែកគ្រប់គ្រងតុលាការ ផ្ញើជូនលោក Ignacio Tredici ប្រធានក្រុមអ្នកច្បាប់អន្តរជាតិនៃ ក.ស.ច.ស (ចម្លងជូន៖ លោកចៅក្រម យូ ប៊ុនឡេង, លោក នួន ផារ័ត្ន, លោក Laurent Kasper-Ansermet, លោក Bernard Brun, លោក Krystal Thompson, លោក សាន់ រ៉ាដា, លោក ពាង តុលា, លោក ឡុង សារឿន, លោក កូវ កែវរតនៈ, លោក Hiroko Fujii, លោក Rajeev Kumra, លោក ក្រាញ់ តូនី) "សារព្រមានពីអាកប្បកិរិយារបស់លោក" ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២, វេលាម៉ោង ១២:១៥ រសៀល។

ថែងយ៉ាងច្បាស់ថា ចៅក្រមមួយរូបក្នុងចំណោមសហចៅក្រមស៊ើបអង្កេតមានអំណាចនៅក្នុងស្ថាប័នទាំងមូលគឺ ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក។ និមិត្តរូបនៃសិទ្ធិអំណាចតុលាការនេះគឺជាត្រារបស់ការិយាល័យ ដែលចៅក្រមទាំងពីររូបប្រើប្រាស់រួមគ្នា ដែលជាការសំខាន់ សម្រាប់ការបញ្ចូលរាល់សេចក្តីសម្រេចទាំងអស់របស់តុលាការទៅក្នុងសំណុំរឿងឲ្យបានត្រឹមត្រូវ ហើយដែលចៅក្រមទាំងពីររូប និងក្រឡាបញ្ជីទាំងពីររូបសុទ្ធតែអាចប្រើប្រាស់បានដូចគ្នា។ ទោះជាយ៉ាងណាក្តី នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅពេលដែលក្រឡាបញ្ជីអន្តរជាតិនៃ ក.ស.ច.ស បានស្នើសុំត្រាដើម្បីប្រថាប់ពីក្រឡាបញ្ជីជាតិ សំណើរបស់ខ្លួនត្រូវបានបដិសេធ។ បន្ទាប់ពីមានសំណើនានាជាច្រើន ក្រឡាបញ្ជីជាតិនៃ ក.ស.ច.ស បានជំនះដោយបដិសេធមិនព្រមផ្តល់ត្រានោះទៀត ដោយអះអាងថា ខ្លួនត្រូវការការណែនាំពីថ្នាក់លើរបស់ខ្លួនគឺលោកចៅក្រម យូ ប៊ុនឡេង ចំពោះបញ្ហានេះ។ ស្រដៀងគ្នានេះដែរ ជំនួយការរដ្ឋបាលរបស់សហចៅក្រមស៊ើបអង្កេតជាតិ មិនបានប្រគល់ត្រាដោយគ្មានការអនុញ្ញាតពីចៅក្រមជាតិឡើយ[44]។

42. ការបង្គាប់ឲ្យមន្ត្រីរបស់ខ្លួនកាន់កាប់ត្រាការិយាល័យសហចៅក្រមស៊ើបអង្កេត មិនឲ្យចៅក្រមអន្តរជាតិ និងមន្ត្រីប្រើប្រាស់បាន លោកចៅក្រម យូ ប៊ុនឡេង បានរារាំងយ៉ាងមានប្រសិទ្ធភាពក្នុងការធ្វើឲ្យមន្ត្រីចំនួនពាក់កណ្តាល នៅក្នុងការិយាល័យនេះមិនអាចបំពេញការងាររបស់ខ្លួនបានត្រឹមត្រូវ ហើយវាក៏ជាការរំលោភដល់វិធានផ្ទៃក្នុង ច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក ដែរ។

43. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានធ្វើសំណើទី១ ទៅក្រសួងមហាផ្ទៃសុំត្រាថ្មីមួយ ដើម្បីជំនួសត្រាដែលកាន់កាប់ដោយចៅក្រម យូ ប៊ុនឡេង[45]។ ដោយសារពុំមានការឆ្លើយតបចំពោះសំណើទី១ នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២

---

[44] ក.ស.ច.ស, កំណត់សម្គាល់របស់ក្រឡាបញ្ជីផ្ញើជូនសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២។

[45] ក.ស.ច.ស, សំណើសុំត្រាបន្ថែមសម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូន ឯ.ឧ. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលបានចែកជូននៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១០:០០។

គាត់បានធ្វើសំណើទី២ ទៀត[46]។ នៅថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២ ក្រឡាបញ្ជីអន្តរជាតិបានទទួលការហៅទូរស័ព្ទមួយពីនាយកដ្ឋានកិច្ចការអន្តរជាតិនៃក្រសួងមហាផ្ទៃ ដែលបានផ្តល់ព័ត៌មានដោយផ្ទាល់មាត់ថា ក្រសួងមិនអាចយល់ស្របតាមសំណើនេះបានទេ ដោយសារសំណើនេះមិនមានហត្ថលេខាពីចៅក្រមទាំង ២ រូប[47]។ អាស្រ័យហេតុនេះ លោកចៅក្រម យូ ប៊ុនឡេង មិនត្រឹមតែរាំងខ្ទប់ តែរហូតត្រាមិនឱ្យចៅក្រម Kasper-Ansermet ប្រើប្រាស់បំពេញមុខងាររបស់ខ្លួននៅ អ.វ.ត.ក ប៉ុណ្ណោះទេ តែគាត់ក៏បានរារាំងយ៉ាងមានប្រសិទ្ធភាពមិនឱ្យអ្នកដទៃទៀតដោះស្រាយបញ្ហានេះឡើយ។

## ឆ) ការរារាំងដល់ការស៊ើបអង្កេតផ្ទៃក្នុង

44. នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានចេញសេចក្តីសម្រេចមួយបើកកិច្ចស៊ើបសួរចំពោះការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អ.វ.ត.ក[48] បន្ទាប់មកគាត់បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួសនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២[49] ដែលគាត់បានផ្តល់អាណត្តិការងារដល់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ដើម្បីស៊ើបសួរចំពោះទង្វើនានា និងអំពើអសកម្មរបស់មន្ត្រី ៤ រូបដែលបម្រើការខាងភាគីជាតិនៃ អ.វ.ត.ក។ វិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុងបានផ្តល់សិទ្ធិដល់សហ

---

[46] លិខិតពី Ignacio Tredici, ក.ស.ច.ស, មន្ត្រីទទួលបន្ទុក, ផ្ញើជូនខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលបានចែកជូននៅថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១០:០០។

[47] សារអេឡិចត្រូនិកពីលោក លី ច័ន្ទតុលា ក្រឡាបញ្ជីអន្តរជាតិនៃ ក.ស.ច.ស ផ្ញើជូនលោក Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ (ចម្លងជូន៖ លោក Knut Rosandhaug, លោក Rajeev Kumra) "សំណើសុំត្រា ក.ស.ច.ស បន្ថែមពីក្រសួងមហាផ្ទៃ" ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២។

[48] ក.ស.ច.ស, សេចក្តីសម្រេចបើកកិច្ចស៊ើបសួរចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អ.វ.ត.ក, ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២, សម្ងាត់, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ឯកសារលេខ D29។

[49] ក.ស.ច.ស, ដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ឯកសារលេខ D29/1 ត្រូវបានចែកជូនអនុលោមតាមវិធាន ៥៥(៥), ៥៥(៩), ៦២ នៃវិធានផ្ទៃក្នុង។

ចៅក្រមស៊ើបអង្កេតក្នុងការរៀបចំកិច្ចស៊ើបសួរបែបនេះ ដើម្បី "ឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធីឬទេ"។

45. ហេតុនេះ អ្នកស៊ើបអង្កេតអន្តរជាតិ ២ រូបនៃ ក.ស.ច.ស ត្រូវបានចាត់តាំងឱ្យបំពេញកិច្ចស៊ើបសួរនេះ តែត្រូវបានជំទាស់ដោយបុគ្គលិកជាតិទាំងអស់ដែលពាក់ព័ន្ធ។ នៅក្នុងរបាយការណ៍ស្តីពីការបំពេញកិច្ចស៊ើបសួររបស់ខ្លួន[50] អ្នកស៊ើបអង្កេតបានប្រកាសថា ពួកគេបានកោះហៅមន្ត្រី ៤ រូបដែលមានរៀបរាប់ឈ្មោះនៅក្នុងកថាខណ្ឌ ៤៥ ខាងលើ ឱ្យមកបង្ហាញខ្លួនសម្រាប់ស្តាប់ចម្លើយក្នុងការស៊ើបសួរ អនុលោមតាមវិធាន ៣៥ លើកដំបូង*តាមរយៈ* សារអេឡិចត្រូនិកមួយ ដែលបានផ្ញើជូនទៅមន្ត្រីទាំងនោះទៅតាមអាសយដ្ឋានវិជ្ជាជីវៈរបស់ពួកគេ[51]។ មានសំណើចំនួន ៣ ក្នុងចំណោមសំណើទាំងនេះមិនត្រូវបានឆ្លើយតបទេ មានតែប្រធានក្រុមអ្នកច្បាប់ជាតិនៃ ក.ស.ច.ស ទេដែលបានឆ្លើយតបចំពោះអ្នកស៊ើបអង្កេត ដោយបានជូនដំណឹងពួកគេថា ខ្លួននឹងមិនអនុវត្តតាមទេ[52]។ បន្ទាប់មក មានដីកាកោះហៅផ្លូវការត្រូវបានចេញចំពោះមន្ត្រីទាំង ៤ រូបនោះ អនុលោមតាមវិធានផ្ទៃក្នុង[53] និងបានចែកជូនដោយអ្នករត់សំបុត្រនៃ អ.វ.ត.ក[54] តែដីកាកោះហៅទាំងនោះត្រូវបានបញ្ជូនត្រឡប់មកវិញដោយមិនបើកមើលទេ។ នៅក្នុងការបដិសេធមួយយ៉ាងច្បាស់លាស់មិនអនុវត្តតាមដីកាកោះ ប្រធានក្រុមអ្នកច្បាប់ជាតិនៃ ក.ស.ច.ស បាននិយាយយោងបីដងទៅដល់សិទ្ធិអំណាចរបស់ លោក

---

[50] ក.ស.ច.ស, របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១២, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស។

[51] សារអេឡិចត្រូនិកពី លោក Paolo Pastore-Stocchi, អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស, "ការស្តាប់ចម្លើយសាក្សី", ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, វេលាម៉ោង ០១:២៤ រសៀល; សារអេឡិចត្រូនិកពី លោក Paolo Pastore-Stocchi, អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស, "ការស្តាប់ចម្លើយសាក្សី", ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, វេលាម៉ោង ០១:៣១ រសៀល; សារអេឡិចត្រូនិកពី លោក Paolo Pastore-Stocchi, អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស, "ការស្តាប់ចម្លើយសាក្សី", ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, វេលាម៉ោង ០១:៣៣ រសៀល; សារអេឡិចត្រូនិកពី លោក Paolo Pastore-Stocchi, អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស, "ការស្តាប់ចម្លើយសាក្សី", ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២, វេលាម៉ោង ០១:៣៤ រសៀល។

[52] សារអេឡិចត្រូនិក, "យោង៖ ការស្តាប់ចម្លើយសាក្សី", ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២, វេលាម៉ោង ១១:៣២ ព្រឹក។

[53] វិធាន ៤១, ៥៥(៥), ៦០ នៃវិធានផ្ទៃក្នុង។

[54] ក.ស.ច.ស, របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១២, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ឧបសម្ព័ន្ធ ១៣, ១៤, ១៥, ១៦។

ចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិថាជាអ្នកសម្រេចតែម្នាក់គត់ចំពោះគោលនយោបាយនៅ ក.ស.ច.ស ហើយខ្លួនបានបញ្ជាក់ច្បាស់ថា ខ្លួនកំពុងបំពេញការងារនៅក្រោមសិទ្ធិអំណាចរបស់ចៅក្រមរូបនោះ[55]។

46. ជាងនេះទៀត សំណើរបស់អ្នកស៊ើបអង្កេតសុំមន្ត្រីបកប្រែផ្ទាល់មាត់ និងអ្នកធ្វើប្រតិចារឹកមានវត្តមានក្នុងពេលស្តាប់ចម្លើយសាក្សីទាំងនេះក៏ត្រូវបានគេបដិសេធដែរ "ដោយធ្វើតាមការណែនាំ" របស់មន្ត្រីជាន់ខ្ពស់នៃផ្នែកគ្រប់គ្រងតុលាការ[56]។

47. មកដល់ពេលដែលបានកំណត់ អ្នកស៊ើបអង្កេត និងបុគ្គលិកគាំទ្រការងារផ្នែកជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម (មន្ត្រីបកប្រែផ្ទាល់មាត់ ១ រូប និងអ្នកវិភាគ ១ រូប) មានវត្តមាននៅក្នុងបន្ទប់ដែលរៀបចំសម្រាប់ស្តាប់ចម្លើយ តែពុំមានសាក្សីណាម្នាក់ក្នុងចំណោមទាំង ៤ រូបបានបង្ហាញខ្លួនទេ។ នៅពេលទាក់ទងទៅអ្នកទាំងនោះ ពួកគេគ្រាន់តែឆ្លើយថា ពួកគេពុំមានចេតនាចង់អនុវត្តតាមដីកាកោះហៅទាំងនេះទេ[57]។ សាក្សីម្នាក់ក្នុងចំណោមអ្នកទាំងនោះក៏បាននិយាយផងដែរថា "ផ្អែកតាមការណែនាំដែលទទួលបានពីផ្នែកគ្រប់គ្រងជាន់ខ្ពស់ជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គេបានស្នើសុំមិនឱ្យខ្លួនអនុវត្តតាមសំណើពីអ្នកស៊ើបអង្កេតអន្តរជាតិនៃ ក.ស.ច.ស អាស្រ័យហេតុនេះ ខ្លួនមិនចូលរួមផ្តល់ចម្លើយទេ"[58]។ ជាងនេះទៀត សាក្សីដដែលនោះបានប្រកាសថា ខ្លួនបានទទួល

---

[55] "សេចក្តីថ្លែងការណ៍របស់លោកចៅក្រម យូ ប៊ុនឡេង បានបញ្ជាក់ច្បាស់ណាស់ថា លោកចៅក្រមបម្រុង Kasper (sic) Ansermet មិនមានសិទ្ធិអំណាចតាមផ្លូវច្បាប់ទេ ..." "... សហចៅក្រមស៊ើបអង្កេតជាតិ ជាអ្នកគ្រប់គ្រងផ្ទាល់របស់ខ្ញុំនៅក្នុងការិយាល័យនេះ ..." "... បំពេញការងារក្រោមការគ្រប់គ្រងរបស់ចៅក្រមស៊ើបអង្កេតដែលត្រូវបានតែងតាំងតាមច្បាប់តែប៉ុណ្ណោះ"។

[56] សារអេឡិចត្រូនិកពីអង្គភាពប្រតិចារឹក ផ្ញើជូន អ្នកស៊ើបអង្កេតអន្តរជាតិនៃ ក.ស.ច.ស "យោង៖ បន្ទប់សវនាការតូចសម្រាប់ការស្តាប់ចម្លើយ ក.ស.ច.ស ថ្ងៃទី ២៩ ខែ កុម្ភៈ និងថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១២", ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

[57] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២ និង ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១២។

[58] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ, សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ២។

ការណែនាំពីប្រធានការិយាល័យរដ្ឋបាលស្តីទីនៅ អ.វ.ត.ក មិនឱ្យទទួលយកដីកាកោះហៅដែលបានផ្ញើជូនដល់ខ្លួននោះទេ។ ដោយពិចារណាទៅលើស្ថានភាពទាំងនេះនៅក្នុងការស៊ើបសួរនេះ និងទៅលើស្ថានភាពរបស់មន្ត្រីដែលពាក់ព័ន្ធនោះ គេអាចសន្និដ្ឋានបានថា សាក្សី ៣ រូបផ្សេងទៀតទំនងជាបានទទួលការណែនាំស្រដៀងគ្នានេះដែរពីមន្ត្រីដដែល។ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិយល់ច្បាស់ថា សមភាគីជាតិគឺលោកចៅក្រម យូ ប៊ុនឡេង ជាប្រភពនៃការបដិសេធមិនសហការក្នុងការស៊ើបអង្កេតនេះ ទោះបីការស៊ើបសួរនេះត្រូវបានធ្វើឡើង អនុលោមតាមវិធានផ្ទៃក្នុងក៏ដោយ។

## ង) ភាពមិនអាចសុំឱ្យបំពេញការងារបាននៃអ្នកបើកបរ និងអ្នកធ្វើប្រតិចារឹក សម្រាប់កិច្ចស៊ើបសួរ

48. អ្នកស៊ើបអង្កេតអន្តរជាតិនៃ ក.ស.ច.ស ត្រូវបានគេបដិសេធមិនព្រមផ្តល់អ្នកបើកបរ និងអ្នកធ្វើប្រតិចារឹក (បុគ្គលិកជាតិ) បន្ទាប់ពីមានសំណើសុំមន្ត្រីទាំងនេះឱ្យបម្រើសេវាសម្រាប់កិច្ចស៊ើបសួរតាមការអនុញ្ញាតដោយចៅក្រម Kasper-Ansermet រយៈពេលពីថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១២ រហូតដល់ពេលបច្ចុប្បន្ន (មានប្រហែលបេសកកម្មចំនួន ១១)។ ប្រការគួរឱ្យកត់សម្គាល់គឺថា អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ក៏ធ្លាប់ជួបប្រទះនូវការលំបាកផងដែរក្នុងការចាត់ចែងការងារសម្រាប់មន្ត្រីបកប្រែផ្ទាល់មាត់ (បុគ្គលិកអន្តរជាតិ)។

## ឈ) ការមិនសហការពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

49. នៅខែ មីនា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិបានចេញដីកាកោះហៅអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេមកស្តាប់ចម្លើយ នៅក្នុងបរិបទនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣។ គាត់បានស្នើសុំជំនួយពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") ដោយដំណើរការតាមនីតិវិធីត្រឹមត្រូវ ដើម្បីរៀបចំបញ្ជូន និងសម្រួលការចូលរួមរបស់អ្នកដាក់ពាក្យសុំក្នុងការស្តាប់ចម្លើយ។ សំណើនេះត្រូវបានបដិសេធចោល ហើយ ក.ស.ច.ស ទទួលបានព័ត៌មានថា "អង្គភាព WESU ស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលដែលមានស្រាប់ ហេតុនេះបុគ្គលិកជាតិនៃ អ.វ.ត.ក (មិនមែនជាបុគ្គលិករបស់ UNAKRT) មិនអាចត្រូវបានស្នើឱ្យអនុវត្តសកម្មភាពការងាររបស់ ក.ស.ច.ស នៅពេលដែលសំណើនោះត្រូវបានធ្វើឡើង ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិតែម្នាក់ឯង

នោះទេ[59]។ សេចក្ដីប្រកាសនេះត្រូវបានដកចេញវិញក្នុងមួយរយៈពេលខ្លីក្រោយមក[60] ដោយអនុញ្ញាតឱ្យមានការស្ដាប់ចម្លើយទៅតាមកាលបរិច្ឆេទកំណត់។ ទោះជាយ៉ាងណាក្ដី ពុំមានផ្ដល់នូវការពន្យល់ណាមួយ ពីមូលហេតុដែលនាំឱ្យមានការសម្រេចចិត្តបែបនេះទេ។

50. ប្រការនេះបង្ហាញពីការបែងចែកជាទូទៅនៅ អ.វ.ត.ក រវាងមន្ត្រីខាងភាគីជាតិ និងភាគីអន្តរជាតិ ជាការរំលោភដល់ស្មារតីនៃការបង្កើត អ.វ.ត.ក ដែលកើតឡើងដោយសារការប្រឆាំងជាប្រព័ន្ធ និងពុំមានមូលដ្ឋានពីសំណាក់លោកចៅក្រម យូ ប៊ុនឡេង ចំពោះការតែងតាំងលោកចៅក្រម Kasper-Ansermet មកកាន់តំណែងនៅ ក.ស.ច.ស នេះ។

### ញ) នីតិវិធីមិនត្រឹមត្រូវនៅចំពោះមុខគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង

51. ឧទាហរណ៍មួយទៀតនៃអវិភាពដែលបានសំដែងឡើងដោយបុគ្គលិកជាតិនៅ អ.វ.ត.ក ចំពោះសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ដែលមានបំណងបំពេញការងាររបស់ខ្លួនប្រកបដោយយកចិត្តទុកដាក់ និងស្របច្បាប់ គឺត្រូវបានលេចឡើងក្នុង "ការបដិសេធ" ចំពោះសំណើរបស់គាត់សុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដែលបានដាក់កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ ដោយអនុលោមទៅតាមវិធាននីតិវិធីជាធរមាន។

52. វិធាន ៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក បានផ្ដល់សិទ្ធិអំណាចដល់សហចៅក្រមស៊ើបអង្កេតក្នុងការស្នើជាលក្ខណៈផ្ទាល់ខ្លួនដល់គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង សុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ដែលគណៈកម្មាធិការនេះនឹងដាក់សំណើផ្លូវការទៅកិច្ចប្រជុំពេញអង្គដើម្បីអនុម័ត។ ទាំងវិធាននេះ និងវិធាន ២០ *(គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង)* ចែងថា

---

[59] សារអេឡិចត្រូនិកពីអ្នកស្រី Wendy Lobwein អ្នកសម្របសម្រួលអង្គភាពគាំពារសាក្សី និងអ្នកជំនាញ, ផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ, និង លោក លី ច័ន្ទតុលា ក្រឡាបញ្ជីអន្តរជាតិនៃ ក.ស.ច.ស (ចម្លងជូន៖ Sophia Swart, លោក Richard Harten, លោក គង់ សុភី, Krystal Thompson) "យោង៖ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣", ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២, វេលាម៉ោង ០៧:៤៩ ព្រឹក។

[60] សារអេឡិចត្រូនិកពីអ្នកស្រី Wendy Lobwein អ្នកសម្របសម្រួលអង្គភាពគាំពារសាក្សី និងអ្នកជំនាញ, ផ្ញើជូនលោកចៅក្រម Laurent Kasper-Ansermet សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ, "យោង៖ ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣", ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២, វេលាម៉ោង ០២:០១ រសៀល។

គណៈកម្មាធិការមានអំណាចក្នុងការពិចារណាទៅលើសំណើបែបនេះ។ វិធានផ្ទៃក្នុងត្រឹមតែចែងថា គណៈកម្មាធិការត្រូវលើកយកសំណើនានាដាក់ជូនទៅកិច្ចប្រជុំពេញអង្គជាអ្នកពិនិត្យសម្រេចអនុម័តទទួលយក ឬបដិសេធចោល។

53. ប៉ុន្តែ ផ្ទុយពីនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុង គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង បានជ្រើសរើស "បដិសេធ" សំណើរបស់លោកចៅក្រម Kasper-Ansermet ដោយពុំបានផ្តល់នូវយុត្តិកម្មតាមផ្លូវច្បាប់ណាមួយទេ។ គណៈកម្មាធិការនេះក្តី លេខាធិការដ្ឋានរបស់ខ្លួនមិនបានជូនដំណឹងដល់គាត់ទេ ផ្ទុយទៅវិញ គាត់បានទទួលព័ត៌មានក្រៅផ្លូវការពីចៅក្រមផ្សេងទៀតនៅ អ.វ.ត.ក តែប៉ុណ្ណោះ[61]។

54. ទាក់ទិននឹងវិធាននីតិវិធីដែលគ្រប់គ្រងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងវិញ លោកចៅក្រម Kasper-Ansermet បានស្នើសុំឲ្យគណៈកម្មាធិការនេះដាក់សំណើរបស់គាត់ទៅកិច្ចប្រជុំពេញអង្គក៏បាន ឬចេញសេចក្តីសម្រេចដែលមានសំអាងហេតុចំពោះការបដិសេធរបស់ខ្លួនក៏បាន។ ប្រសិនបើមិនធ្វើបែបនេះទេ គេអាចសន្និដ្ឋានបានថា សេចក្តីសម្រេចដែលពុំមានសំអាងហេតុត្រឹមត្រូវរបស់គណៈកម្មាធិការមិនមានអ្វីក្រៅតែជាធាតុផ្សំមួយទៀត ដែលបង្ហាញពីការសម្រេចចិត្តជាទូទៅរបស់បុគ្គលិកជាតិនៅ អ.វ.ត.ក ក្នុងការជំទាស់ទៅនឹងសកម្មភាព ឬកិច្ចស៊ើបសួរណាមួយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បន្ទាប់ពីលោកចៅក្រម យូ ប៊ុនឡេង បានបដិសេធជាសាធារណៈមិនព្រមផ្តល់ការសហការ ឬការគាំទ្រណាមួយដល់សមភាគីរបស់គាត់។

សម្រាប់សំអាងហេតុនានាដែលបានលើកឡើងខាងលើ យើងជាចៅក្រមដែលចុះហត្ថលេខាខាងក្រោមសូម៖

[61] អនុស្សរណៈអន្តរការិយាល័យ, ចៅក្រម Laurent Kasper-Ansermet, សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ, ផ្ញើជូនប្រធាន និងសមាជិក គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង និង លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល "សំណើសុំធ្វើវិសោធនកម្មវិធាន ៥៦ នៃវិធានផ្ទៃក្នុង អ.វ.ត.ក," ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២។

00797529

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. និង០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No:D114

**កត់សម្គាល់ និង ជូនដំណឹង**ដល់ភាគីថា នៅ អ.វ.ត.ក មានភាពមិនប្រក្រតី ភាពមិនដំណើរការ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើនីតិវិធីត្រឹមត្រូវ ដែលធ្វើឲ្យគ្រោះថ្នាក់ និងធ្វើឲ្យជាប់គាំងដល់ដំណើរការតាមផ្លូវច្បាប់ ហើយស្ថានភាពទាំងនេះប៉ះពាល់ដល់ការរៀបចំកិច្ចស៊ើបសួរត្រឹមត្រូវក្នុងសំណុំរឿង ០០៣ និង ០០៤ តាំងពីពេលដែលយើងបានចូលតំណែងម្ល៉េះ។

**ប្រកាសថា** ឯកសារនេះត្រូវបានចាត់ថ្នាក់ជាឯកសារសាធារណៈ។

**ណែនាំ**ក្រឡាបញ្ជីអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត និងបុគ្គលិកដែលពាក់ព័ន្ធនៅផ្នែកគ្រប់គ្រងតុលាការនៃ អ.វ.ត.ក បញ្ចូលឯកសារនេះទៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលភាគីទាំងអស់អាចចូលប្រើប្រាស់បាន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២

**សហចៅក្រមស៊ើបអង្កេត**

**Co-juge d'instruction international suppléant**

**International Reserve Co- Investigating Judge**

**Laurent Kasper-Ansermet**